**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ......៣៧៦........អពដ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការបដិសេធនូវការផ្សាយព័ត៌មានមួលបង្កាច់មកលើមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ

ថ្មីៗនេះមានសារព័ត៌មានក្នុងស្រុកមួយចំនួនតូច បានធ្វើការផ្សព្វផ្សាយព័ត៌មានដែលក្នុងនោះបានយករូបភាពនៃកិច្ចប្រជុំបូកសរុបការងារប្រមូលចំណូលប្រចាំខែមករា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារមកបញ្ចូលខ្លឹមសារមួលបង្កាច់របស់ជនខិលខូចមួយចំនួន ដែលបានចោទប្រកាន់មន្ត្រីជាន់ខ្ពស់របស់អគ្គនាយកដ្ឋានពន្ធដារថាបានទទួលប្រាក់ពីការបង្វិលសងអាករលើតម្លៃបន្ថែម ការស្នើសុំរួចប្រាក់ពិន័យ ការបន្ធូរបន្ថយប្រាក់ពន្ធការធ្វើសវនកម្មលើសហគ្រាសសំណង់ និងការផ្លាស់ប្តូរតួនាទីរបស់មន្ត្រីមួយចំនួនក្នុងអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការបដិសេធទាំងស្រុងនូវព័ត៌មានខាងលើ និងសូមអះអាងថា មន្ត្រីជាន់ខ្ពស់របស់អគ្គនាយកដ្ឋានពន្ធដាររូបនោះពុំមានសិទ្ធិណាមួយជាអត្តនោម័តិ ក្នុងការសម្រេចលើកិច្ចការទាំងឡាយ ដូចការចោទប្រកាន់ខាងលើឡើយ។ រាល់ការសម្រេចកិច្ចការនានាសុទ្ធតែធ្វើឡើងតាមឋានានុក្រម និងតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់ជាធរមាន ។ ព័ត៌មានមិនពិតនេះបានប្រឌិតឡើងដោយសារថ្នាំងថ្នាក់របស់ជនខិលខូចមួយចំនួនតូច ទៅនឹងការកែទម្រង់ស៊ីជម្រៅរបស់អគ្គនាយកដ្ឋានពន្ធដារតាមទិសដៅរបស់រាជរដ្ឋាភិបាលអាណត្តិទី៥ ដែលការកែទម្រង់នេះបណ្តាលឱ្យបាត់ផលប្រយោជន៍ផ្ទាល់ខ្លួនដែលបានមកពីអំពើអសកម្មរបស់ជនខិលខូចទាំងនោះ។

អគ្គនាយកដ្ឋានពន្ធដារនឹងមិនរាថយឡើយ ចំពោះការអនុវត្តនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅនេះ ដែលជាឧបករណ៍ដ៏មានសារសំខាន់សម្រាប់អគ្គនាយកដ្ឋានក្នុងការសម្រេចឱ្យបានជោគជ័យនូវការប្រមូលចំណូលពន្ធដារដែលបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងរាល់បណ្តាញសារព័ត៌មានទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៤
**អគ្គនាយកដ្ឋានពន្ធដារ**

**<u>ចម្លងជូន÷</u>**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"